International Labour Organization



ការកសាងភាពធន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩

គោលការណ៍ណែនាំអំពីកូវីដ-១៩ និងបញ្ជីសកម្មភាព

សម្រាប់រោងចក្រកាត់ដេរ និងអ្នកគ្រប់គ្រង

# ការគ្រប់គ្រងលំហូរសាច់ប្រាក់របស់អ្នក

ដើម្បីឱ្យរោងចក្រកាត់ដេរដោះស្រាយទល់នឹងវិបត្តិកូវីដ-១៩ គោលការណ៍ណែនាំនេះនឹងជួយណែនាំដល់អ្នកគ្រប់គ្រងរោងចក្រ ក្នុងការតាមដានលំហូរសាច់ប្រាក់របស់ខ្លួនដើម្បីដោះស្រាយស្ថានភាពឱ្យបានល្អក្នុងអំឡុងពេលនៃវិបត្តិនេះ។

## ការចាប់ផ្តើម

រួមមាន៖
គំរូតារាងទិន្នន័យ
បញ្ជីត្រួតពិនិត្យសកម្មភាព

**គោលការណ៍ណែនាំនេះផ្តោតលើ៖**

- ហេតុអ្វីបានជាការគ្រប់គ្រងលំហូរសាច់ប្រាក់មានសារៈសំខាន់ក្នុងអំឡុងពេលនៃវិបត្តិជំងឺរាតត្បាតនេះ
- វិធីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ និងការព្យាករណ៍លំហូរសាច់ប្រាក់
- អនុសាសន៍ស្តីពីវិធីពង្រឹងលំហូរសាច់ប្រាក់របស់អ្នកភ្លាមៗ និងនាពេលអនាគត

## ១- ហេតុអ្វីបានជាការតាមដានស្ថានភាពសាច់ប្រាក់របស់អ្នកមានសារៈសំខាន់ក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ?

ការតាមដានលំហូរសាច់ប្រាក់របស់រោងចក្រអ្នកពិតជាសំខាន់ណាស់ពីព្រោះវាអាចបង្កលក្ខណៈ

ងាយស្រួលដល់អ្នកក្នុងការតាមដានចំណាយ ក៏ដូចជាដើម្បីចៀសវាង ឬកាត់បន្ថយការខាតបង់ផងដែរ ហើយការតាមដាននេះក៏អាចជួយអ្នកឱ្យប្រាកដថារោងចក្ររបស់អ្នកនៅតែអាចបង្វិលប្តូរជាសាច់ប្រាក់បាន ដែលនឹងអាចជួយអ្នកក្នុងការបង្កើនប្រាក់ចំណេញ។ លំហូរសាច់ប្រាក់របស់អ្នកគឺជាអ្វីដែលកំណត់ចំនួនទឹកប្រាក់ដែលអ្នកមានដើម្បីអ្នកអាចចំណាយក្នុងពេលវេលាដែលបានកំណត់មួយ។

**"ការយល់ដឹងអំពីលំហូរសាច់ប្រាក់របស់អ្នកបានច្បាស់លាស់ អាចជួយឱ្យរោងចក្ររបស់អ្នកបន្តរស់រានក្នុងអំឡុងពេលនៃការរាតត្បាតនៃមេរោគកូវីដ-១៩។**




ក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩នេះ វាពិតជាមានភាពចាំបាច់ណាស់ដែលរោងចក្រត្រូវពិនិត្យពិចារណាលើលំហូរសាច់ប្រាក់របស់ខ្លួន។ រោងចក្រជាច្រើនដែលបានបញ្ឈប់អាជីវកម្មភាគច្រើនគឺបរាជ័យនៅក្នុងបញ្ហានេះ ពីព្រោះតែពួកគេមិនមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់ថ្លៃចំណាយរបស់ពួកគេ។ ការយល់ច្បាស់អំពីលំហូរសាច់ប្រាក់របស់អ្នកនាពេលបច្ចុប្បន្ន និងអនាគត អាចជួយឱ្យរោងចក្ររបស់អ្នកបន្តរស់រានក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ហើយការយល់ច្បាស់នេះនឹងអាចធ្វើឱ្យរោងចក្ររបស់អ្នកមានភាពកាន់តែងាយស្រួលក្នុងការបន្តប្រតិបត្តិការផងដែរ។

ការស្វែងយល់អំពីលំហូរសាច់ប្រាក់របស់អ្នកគឺជាចំណុចចាប់ផ្តើម ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរោងចក្ររបស់អ្នកប្រកបដោយការទទួលខុសត្រូវ ក្នុងកំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាក្នុងរយៈពេលវែង។ ការស្វែងយល់នេះអាចជួយឱ្យអ្នកមានការប្រុងប្រយ័ត្នជាមុន អំពីកង្វះសាច់ប្រាក់នាពេលអនាគត ហើយវាអាចជួយអ្នកឱ្យចាត់វិធានការបានទាន់ពេលវេលា ដើម្បីធ្វើសកម្មភាពជាមុនមុនពេលអ្នកប្រឈមមុខនឹងស្ថានភាពលំហូរចេញនៃសាច់ប្រាក់/ស្ថានភាពខាតបង់ខ្លាំង។

## ២- ការយល់ច្បាស់អំពីលំហូរសាច់ប្រាក់

លំហូរសាច់ប្រាក់គឺជាចំនួនសាច់ប្រាក់ដែលកំពុងត្រូវបានផ្ទេរចូល និងផ្ទេរចេញពីរោងចក្ររបស់អ្នក។ ប្រសិនបើប្រាក់កំពុងហូរចូលមកកាន់តែច្រើនជាងអ្វីដែលកំពុងហូរចេញ នោះរោងចក្ររបស់អ្នកមាន 'លំហូរសាច់ប្រាក់វិជ្ជមាន' ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើរោងចក្ររបស់អ្នកចំណាយប្រាក់ច្រើនជាងអ្វីដែលកំពុងហូរចូលមក នោះរោងចក្ររបស់អ្នកនឹងមាន "លំហូរសាច់ប្រាក់អវិជ្ជមាន" ។

អ្នកតែងតែប្រាថ្នាចង់មានលំហូរសាច់ប្រាក់វិជ្ជមាន ដើម្បីអាចទូទាត់ថ្លៃចំណាយរោងចក្ររបស់អ្នក។ ពេលខ្លះរោងចក្រដែលរកប្រាក់ចំណេញអាចមានលំហូរសាច់ប្រាក់អវិជ្ជមាន ឧទាហរណ៍ ប្រសិនបើរោងចក្រនោះចំណាយច្រើនក្នុងការទិញវត្ថុធាតុដើម ឬស្តុក។ ដោយសារវត្ថុធាតុដើមមានតម្លៃច្រើន គិតជាប្រាក់ លុះត្រាតែវាបង្កើតប្រាក់ចំណូលបានឆាប់រហ័ស បើមិនដូច្នោះទេ ប្រាក់ចំណេញនឹងត្រូវបានយកមកប្រើប្រាស់អស់ ហើយរោងចក្រអាចមានលំហូរសាច់ប្រាក់អវិជ្ជមានរហូតដល់ពេលដែលស្តុកត្រូវបានប្រើដើម្បីផលិតសម្លៀកបំពាក់ ដឹកជញ្ជូនទៅឱ្យអ្នកទិញរបស់អ្នក ហើយទទួលបានផលនៃការលក់ទាំងនេះជាថ្មីម្តងទៀត។ បញ្ហានេះតម្រូវឱ្យអ្នកស្វែងរកវិធីកាត់បន្ថយវដ្តនៃមូលធនបង្វិលរបស់អ្នក។

ដើម្បីគណនាលំហូរសាច់ប្រាក់ អ្នកត្រូវបូកសរុបៈ

- **លំហូរចូលនៃសាច់ប្រាក់៖** ប្រាក់ទាំងអស់ដែលរោងចក្ររបស់អ្នកបង្កើតបាន រាប់បញ្ចូលទាំងចំណូលបានពីការលក់ ប្រាក់កម្ចីធនាគារ និងប្រភពចំណូលផ្សេងៗទៀត (ឧទាហរណ៍៖ ការបញ្ជាទិញដោយភាគីទទួលកិច្ចសន្យាបន្ត ឬផ្នែកផ្សេងៗដែលពាក់ព័ន្ធ (ប្រសិនបើត្រូវបានអនុញ្ញាត) ការលក់គ្រឿងតុបតែងសំលៀកបំពាក់ដែលលើសចំនួនកំណត់ ការលក់សម្លៀកបំពាក់គុណភាពលេខ២ និង ប្រាក់កម្ចីធនាគារ។
- **លំហូរចេញនៃសាច់ប្រាក់របស់រោងចក្រ៖**
  ប្រាក់ទាំងអស់ដែលរោងចក្ររបស់អ្នកចំណាយលើថ្លៃដើមថេរ និងថ្លៃដើមអថេរ មានដូចជាវត្ថុធាតុដើម ប្រាក់ឈ្នួល ថ្លៃទឹក និងថ្លៃភ្លើងអគ្គីសនី និងថ្លៃចំណាយផ្សេងៗ។

ការគ្រប់គ្រងលំហូរសាច់ប្រាក់របស់អ្នកទាក់ទងនឹងការសង្កេតប្រវត្តិសាច់ប្រាក់របស់រោងចក្រអ្នកដើម្បីវិភាគលើគំរូណាមួយ និងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីលំហូរចូលនៃសាច់ប្រាក់ និងលំហូរចេញនៃសាច់ប្រាក់របស់អ្នក។ **របាយការណ៍លំហូរសាច់ប្រាក់** អនុញ្ញាតឱ្យអ្នកបូកសរុបលំហូរសាច់ប្រាក់ពីមុនៗរបស់អ្នក សម្រាប់គោលបំណងនេះ។ ដើម្បីព្យាករណ៍អំពីលំហូរសាច់ប្រាក់របស់អ្នកនាពេលអនាគត អ្នកគួររៀបចំ **ការព្យាករណ៍លំហូរសាច់ប្រាក់មួយ** ។ វាទាក់ទងនឹងការព្យាករណ៍ចំណាយរបស់អ្នកនាពេលអនាគត រួមមានកម្លាំងពលកម្ម វត្ថុធាតុដើម និងថ្លៃចំណាយប្រតិបត្តិការ

ដើម្បីអាចដឹងថាតើអ្នកត្រូវការសាច់ប្រាក់ប៉ុន្មាន ដើម្បីអាចទូទាត់ការចំណាយរបស់អ្នកបាន។ លើសពីនេះទៀត អ្នកត្រូវព្យាករណ៍លំហូរចូលនៃសាច់ប្រាក់របស់អ្នក ក្នុងរយៈពេលដូចគ្នានោះ។ តាមរយៈការប្រៀបធៀបតួលេខទាំងនេះ អ្នកនឹងដឹងថាតើអ្នកមានសាច់ប្រាក់គ្រប់គ្រាន់ ឬទេ សម្រាប់រ៉ាប់រងការចំណាយរបស់អ្នកនៅប៉ុន្មានខែខាងមុខ ឬថាតើអ្នកត្រូវការស្វែងរកប្រភពចំណូលផ្សេងទៀត ដូចជាប្រាក់ឧបត្ថម្ភធន ឬកម្ចី រយៈពេលខ្លីទៅមធ្យម។

## ៣- ការត្រៀមអនុវត្តសកម្មភាព

ដោយសារអ្នកបានយល់កាន់តែច្បាស់ថាតើការគ្រប់គ្រងលំហូរសាច់ប្រាក់ជាអ្វី និងហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់រោងចក្រកាត់ដេររបស់អ្នក ផ្នែកបន្ទាប់នឹងផ្តល់នូវជំហានជាក់លាក់មួយចំនួនអំពីវិធីគ្រប់គ្រងលំហូរសាច់ប្រាក់របស់អ្នក ប្រកបដោយភាពទទួលខុសត្រូវ។



# ៤ ជំហានសម្រាប់រោងចក្រដើម្បីពង្រឹងការគ្រប់គ្រងលំហូរសាច់ប្រាក់របស់ខ្លួន

## ០១ រៀបចំរបាយការណ៍លំហូរសាច់ប្រាក់របស់រោងចក្រអ្នក

ស្វែងយល់ថាតើអ្នកមានសាច់ប្រាក់ប៉ុន្មាន

## ០២ រៀបចំការព្យាករណ៍លំហូរសាច់ប្រាក់របស់រោងចក្រអ្នក

ដើម្បីរៀបចំផែនការសម្រាប់ ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ដោយសារវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗទៀត។

## ០៣ ធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងអនុវត្តការត្រួតពិនិត្យ

ប្រើប្រាស់ព័ត៌មានដែលអ្នកមាន

## ០៤ ពង្រឹងលំហូរសាច់ប្រាក់របស់អ្នកភ្លាមៗ និងនាពេលអនាគត

ពិចារណាអំពីស្ថានភាពបច្ចុប្បន្ន ក៏ដូចជានាពេលអនាគត

# ចាប់ផ្តើមអនុវត្តវិធានការ៖ បញ្ជីត្រួតពិនិត្យរោងចក្រ

## 1. រៀបចំរបាយការណ៍លំហូរសាច់ប្រាក់របស់រោងចក្រអ្នក

ដំបូងត្រូវរៀបចំរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នក។ ការរៀបចំនេះនឹងជួយអ្នកវិភាគថាតើរោងចក្ររបស់អ្នកបង្កើតចំណូលសាច់ប្រាក់បានប៉ុន្មានក្នុងពេលកន្លងមក និងចំនួនសាច់ប្រាក់ប៉ុន្មានដែលបានចំណាយ។ វានឹងជួយអ្នកឱ្យយល់អំពីចំនួនប្រាក់ដែលអ្នកមាន ហើយវាក៏ជាចំណុចចាប់ផ្តើមផងដែរសម្រាប់ធ្វើការព្យាករណ៍នាពេលអនាគតអំពីលំហូរសាច់ប្រាក់របស់អ្នក។

Factory_Cash_Flow_Template.xlsx

**គន្លឹះមានប្រយោជន៍៖** សូមប្រើប្រាស់ទម្រង់គំរូដែលបានភ្ជាប់មកជាមួយនេះ (សន្លឹក Excel) ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នក។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ពិនិត្យកំណត់ត្រានៃការលក់ និងការចំណាយរបស់រោងចក្រអ្នក។ ត្រូវប្រាកដថាតួលេខដែលអ្នកមានគឺជាតួលេខបច្ចុប្បន្ន។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| បំពេញរាល់លំហូរចូលនៃសាច់ប្រាក់ទាំងអស់របស់អ្នកសម្រាប់ខែនេះប្រសិនបើមាន និងបំពេញសម្រាប់ខែមុនៗផងដែរ ប្រសិនបើអាច។ ត្រូវប្រាកដថាអ្នករួមបញ្ចូលទាំងសាច់ប្រាក់ដែលមានសម្រាប់ថ្លៃចំណាយ (ជាសាច់ប្រាក់ និងនៅក្នុងធនាគារ) នៅដើមខែនីមួយៗ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| បំពេញរាល់លំហូរចេញនៃសាច់ប្រាក់របស់អ្នកទាំងអស់នៅខែនេះរួមទាំងថ្លៃដើមថេរ និងថ្លៃដើមអថេរ និងបំពេញសម្រាប់ខែមុនៗផងដែរប្រសិនបើអាច។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| សូមពិនិត្យមើលរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នកសម្រាប់ខែនេះ និងខែមុនៗប្រសិនបើអ្នកក៏បានបំពេញព័ត៌មាននេះផងដែរដើម្បីឱ្យយល់ច្បាស់ថាតើអ្នកមានលំហូរសាច់ប្រាក់វិជ្ជមាន ឬអវិជ្ជមាន។ (ដោយសារវិបត្តិជំងឺកូវីដ-១៩ បច្ចុប្បន្នរោងចក្ររបស់អ្នកប្រហែលជាមានលំហូរសាច់ប្រាក់អវិជ្ជមាន) ។ | ✓✓ | »» រយៈពេលខ្លី | ☐ |
| ប្រសិនបើអ្នកមានលំហូរសាច់ប្រាក់អវិជ្ជមានក្នុងខែនេះ អ្នកត្រូវពិនិត្យមើលស្ថានភាពសាច់ប្រាក់បច្ចុប្បន្នរបស់អ្នក និងត្រូវកំណត់រកវិធីល្អបំផុតដើម្បីដោះស្រាយ។ សួរខ្លួនអ្នក៖<br>▶ តើអ្នកត្រូវការសាច់ប្រាក់ប៉ុន្មានដើម្បីទូទាត់ចំណាយរបស់អ្នកឱ្យបានទាន់ពេលវេលាក្នុងខែនេះ?<br>▶ តើចំណាយអ្វីខ្លះដែលអាចពន្យារបាន?<br>▶ តើអ្នកអាចស្វែងរកប្រភពចំណូលផ្សេងទៀតមធ្យោបាយណាមួយ ដើម្បីទូទាត់ចំណាយរបស់អ្នកបានដែរឬទេ? | ✓✓ | »» រយៈពេលខ្លី | ☐ |

## 2. រៀបចំការព្យាករណ៍លំហូរសាច់ប្រាក់របស់រោងចក្រអ្នក

ដើម្បីរៀបចំទប់ទល់ពីផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗទៀត វិធីល្អបំផុតនោះគឺត្រូវប្រាកដថាអ្នកបានយល់ច្បាស់អំពីហិរញ្ញវត្ថុរបស់រោងចក្រអ្នកបានយ៉ាងត្រឹមត្រូវ និងបានយល់ច្បាស់ថាតើវានឹងទទួលរងឥទ្ធិពលយ៉ាងដូចម្តេចដោយសារការគំរាមកំហែងនេះ។ សម្រាប់គោលបំណងនេះ អ្នកអាចប្រើការព្យាករណ៍លំហូរសាច់ប្រាក់បាន។ ក្នុងជំហាននេះ អ្នកនឹងរៀបចំការព្យាករណ៍លំហូរសាច់ប្រាក់មួយសម្រាប់រយៈពេលប្រាំមួយខែខាងមុខនេះ។

**គន្លឹះមានប្រយោជន៍៖** សូមប្រើប្រាស់ទម្រង់គំរូដែលបានភ្ជាប់មកជាមួយនេះ (សន្លឹក Excel) ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នក។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ពិនិត្យមើលរបាយការណ៍លំហូរសាច់ប្រាក់របស់អ្នកដើម្បីវិភាគការចំណាយ និងប្រាក់ចំណូលរបស់អ្នកនាពេលកន្លងមក។ សួរខ្លួនអ្នក៖<br>▶ តើរោងចក្ររបស់យើងរកប្រាក់ចំណូលជាមធ្យមបានប៉ុន្មានក្នុងរយៈពេល ៣ ខែកន្លងមកនេះ?<br>▶ តើរោងចក្ររបស់យើងបានចំណាយប្រាក់ជាមធ្យមប៉ុន្មានក្នុងរយៈពេល ៣ ខែចុងក្រោយនេះ?<br>**គន្លឹះមានប្រយោជន៍៖** ប្រសិនបើអ្នកគណនារយៈពេលកាន់តែច្រើនខែដែលកន្លងមក នោះរបាយការណ៍លំហូរសាច់ប្រាក់នឹងកាន់តែបង្ហាញអំពីមធ្យមភាគនៃអាជីវកម្មរបស់អ្នកកាន់តែប្រសើរ។ | ✓✓ | »»» រយៈពេលខ្លី | ☐ |
| ព្យាយាមព្យាករណ៍ថាតើហិរញ្ញវត្ថុរបស់រោងចក្រអ្នកទទួលរងផលប៉ះពាល់ដោយសារវិបត្តិជំងឺកូវីដ-១៩ ដល់កម្រិតណាក្នុងប៉ុន្មានខែខាងមុខនេះ។ សម្រាប់គោលបំណងនេះ អ្នកអាច៖<br>▶ ពិនិត្យមើលពីរបៀបដែលស្ថានភាពសាច់ប្រាក់របស់អ្នកបានផ្លាស់ប្តូរដោយសារតែការផ្លាស់ប្តូរនៃការលក់ ការទូទាត់ប្រាក់ ការប្រមូល និងប្រតិបត្តិផ្សេងៗដែលត្រូវបានទទួលរងផលប៉ះពាល់ចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិ<br>▶ ស្វែងរកព័ត៌មានតាមអ៊ីនធឺណិត និងតាមរយៈសមាគមកាត់ដេររបស់អ្នកដើម្បីដឹងអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងឧស្សាហកម្មនេះ<br>▶ ពិគ្រោះយោបល់ជាមួយអ្នកទិញ អ្នកផ្គត់ផ្គង់ និងកម្មកររបស់អ្នកដើម្បីអាចប៉ាន់ស្មានឱ្យកាន់តែច្បាស់ថាតើអ្នកនឹងផលិត និងលក់បានប៉ុន្មាននៅប៉ុន្មានខែខាងមុខនេះ។ | ✓ | »»» រយៈពេលខ្លី | ☐ |
| បំពេញការព្យាករណ៍អំពីលំហូរចូលនៃសាច់ប្រាក់របស់អ្នកក្នុងរយៈពេលប្រាំមួយខែខាងមុខ។ សូមចាំថាប្រសិនបើអ្នកប្រមូលព័ត៌មានបានកាន់តែច្រើនទុកជាមុននោះ អ្នកនឹងមានភាពកាន់តែងាយស្រួលក្នុងការព្យាករណ៍បានយ៉ាងត្រឹមត្រូវសម្រាប់ពេលអនាគត។ | ✓✓ | »»» រយៈពេលខ្លី | ☐ |
| បំពេញការការព្យាករណ៍អំពីលំហូរចេញនៃសាច់ប្រាក់របស់អ្នកសម្រាប់រយៈពេលប្រាំមួយខែខាងមុខ។ | ✓✓ | »»» រយៈពេលខ្លី | ☐ |
| ឥឡូវនេះដល់ពេលដែលអ្នកត្រូវពិនិត្យកែសម្រួលឡើងវិញលើការព្យាករណ៍លំហូរសាច់ប្រាក់របស់អ្នក។ តើអ្នកកំពុងព្យាករណ៍ថាតើរោងចក្ររបស់អ្នកនឹងមានលំហូរសាច់ប្រាក់វិជ្ជមាន ឬអវិជ្ជមានក្នុងអំឡុងពេលប្រាំមួយខែខាងមុខនេះដែរឬទេ? សួរខ្លួនអ្នក៖<br>▶ តើរោងចក្ររបស់យើងអាចបន្តរស់រាននៅពេលមានលំហូរសាច់ប្រាក់អវិជ្ជមានក្នុងរយៈពេលប្រាំមួយខែ (ឬក្នុងរយៈពេលដែលអ្នកបានព្យាករណ៍) ដែរឬទេ?<br>▶ តើយើងមានប្រាក់ប៉ុន្មានដើម្បីធានាលើថ្លៃដើមថេរប្រចាំខែរបស់រោងចក្រយើង?<br>▶ តើមានប្រភពណាផ្សេងទៀតនៃលំហូរចូលនៃសាច់ប្រាក់ដែលអាចជួយយើងដោះស្រាយបញ្ហាលំហូរចេញនៃសាច់ប្រាក់អវិជ្ជមាន? | ✓✓ | »»» រយៈពេលខ្លី | ☐ |
| ត្រូវប្រាកដថាបានពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពការព្យាករណ៍អំពីលំហូរសាច់ប្រាក់របស់អ្នកឱ្យបានទៀងទាត់នៅពេលអ្នកទទួលបានព័ត៌មានថ្មី និងផ្អែកលើលទ្ធផលជាក់ស្តែង។ វិធីនេះនឹងជួយឱ្យអ្នករៀបចំផែនការបានល្អប្រសើរជាងមុន និងធ្វើការព្យាករណ៍កាន់តែត្រឹមត្រូវនាពេលអនាគត។ | ✓✓ | »»» »»» រយៈពេលមធ្យម | ☐ |

## 3. ធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងអនុវត្តការត្រួតពិនិត្យ

របាយការណ៍លំហូរសាច់ប្រាក់ និងការព្យាករណ៍លំហូរសាច់ប្រាក់របស់អ្នកគឺជាឧបករណ៍ដ៏មានតម្លៃសម្រាប់ឱ្យអ្នកដោះស្រាយស្ថានភាពរោងចក្ររបស់អ្នក។ ប្រើព័ត៌មានដែលមានដើម្បីធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុឱ្យបានកាន់តែត្រឹមត្រូវ។ ក្នុងជំហាននេះ អ្នកនឹងគណនាលេខសំខានៗមួយចំនួនសំរាប់រោងចក្ររបស់អ្នកដើម្បីស្វែងយល់កាន់តែច្បាស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នកក្នុងរយៈពេលវែងជាងនេះ។

**គន្លឹះមានប្រយោជន៍៖** សូមប្រើទម្រង់គំរូលំហូរសាច់ប្រាក់ដែលបានភ្ជាប់មកជាមួយនេះ (សន្លឹក Excel) ដើម្បីគណនាលេខទាំងនេះសម្រាប់រោងចក្ររបស់អ្នក។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| គណនា **ភាពខុសគ្នានៃលំហូរសាច់ប្រាក់របស់អ្នក**។ ភាពខុសគ្នានៃលំហូរសាច់ប្រាក់គឺជារង្វាស់លទ្ធភាពរកប្រាក់ចំណេញដ៏សំខាន់មួយ ហើយវាបង្ហាញថាតើរោងចក្ររបស់អ្នកអាចបម្លែងការលក់ទៅជាសាច់ប្រាក់បានល្អកម្រិតណា។ ភាពខុសគ្នានៃលំហូរសាច់ប្រាក់របស់អ្នកគឺជាអនុបាតរវាងលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការសរុបលើការលក់។ ភាគរយកាន់តែខ្ពស់បង្ហាញថាអ្នកអាចទទួលបានសាច់ប្រាក់កាន់តែច្រើនពីការលក់។ អ្នកគួរតែកត់ត្រាលំហូរសាច់ប្រាក់របស់អ្នកយ៉ាងហោចណាស់ប្រាំមួយខែមុនពេលគណនាតួលេខនេះ។ | ✓✓ | »»» »»» »»»<br>រយៈពេលមធ្យម/<br>រយៈពេលវែង | ☐ |
| គណនា **អត្រាខាតបង់** របស់អ្នក ។ អត្រាខាតបង់របស់អ្នកបង្ហាញអ្នកអំពីកម្រិតខ្ពស់នៃលំហូរសាច់ប្រាក់អវិជ្ជមានប្រចាំខែរបស់អ្នក។ អត្រាខាតបង់គឺមានប្រយោជន៍ពីព្រោះវាអាចឱ្យដឹងថាតើអ្នកត្រូវមានប្រាក់ប៉ុន្មានដើម្បីអាចបន្តរស់រានដោយគ្មានការបង្កើតប្រាក់ចំណូល។ | ✓✓ | »»» »»» »»»<br>រយៈពេលមធ្យម/<br>រយៈពេលវែង | ☐ |

## 4. ព្យាយាមពង្រឹងលំហូរសាច់ប្រាក់របស់អ្នកភ្លាមៗ និងនាពេលអនាគត

ជាមួយនឹងព័ត៌មានដែលអ្នកមាននៅពេលនេះ  អ្នកក៏គួរតែខិតខំប្រឹងប្រែងពង្រឹងលំហូរសាច់ប្រាក់របស់អ្នកភ្លាមៗ និងនាពេលអនាគត។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ព្យាយាមស្វែងរកប្រភពផ្សេងៗនៃប្រាក់ចំណូល។ ឧទាហរណ៍៖ រដ្ឋាភិបាលរបស់អ្នកប្រហែលជាបានដាក់ចេញនូវកម្មវិធីទ្រទ្រង់ហិរញ្ញវត្ថុ និងការបង្វិលសងប្រាក់ពន្ធដល់រោងចក្រកាត់ដេរនានា។ ទាក់ទងសមាគមកាត់ដេរក្នុងប្រទេសរបស់អ្នក ឬរោងចក្រផ្សេងៗដើម្បីស្វែងយល់បន្ថែម។<br><br>**គន្លឹះមានប្រយោជន៍៖** សូមពិនិត្យមើល គោលការណ៍ណែនាំស្តីពី 'ការស្វែងរកប្រភពនៃប្រាក់ចំណូលផ្សេងៗ' ជាផ្នែកមួយនៃស៊េរីនៃគោលការណ៍ណែនាំនេះ ដើម្បីស្វែងរកវិធីក្នុងការបង្កើនលំហូរចូលនៃសាច់ប្រាក់សម្រាប់រោងចក្ររបស់អ្នក។ | ✓✓ | »»»<br>រយៈពេលខ្លី | ☐ |
| ប្រសិនបើអ្នកអាចធានាបាននូវកន្លែងធ្វើការដែលមានសុវត្ថិភាពសម្រាប់កម្មកររបស់អ្នក សូមស្វែងរកឱកាសនៃការលក់ឱ្យបានសកម្ម។ ទាក់ទងជាមួយអ្នកទិញមុនៗ ក៏ដូចជាអ្នកទិញសក្តានុពលថ្មីៗ។ | ✓✓ | »»» »»»<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| ប្រមូលគណនីដែលត្រូវទទួល និងត្រូវប្រាកដថាអ្នកទិញរបស់អ្នកទូទាត់ប្រាក់ទាន់ពេលវេលា។ ការប្រមូលគណនីអតិថិជនដែលត្រូវទទួលយឺតយ៉ាវអាចបណ្តាលឱ្យមានសម្ពាធដ៏ធ្ងន់លើលំហូរសាច់ប្រាក់របស់រោងចក្រអ្នក។ | ✓ | »»» »»»<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| ប្រសិនបើការប្រមូលប្រាក់របស់អ្នកត្រូវបានពន្យារពេល   ត្រូវពិចារណាផ្តល់ការបញ្ចុះតម្លៃខ្លះដល់អ្នកទិញរបស់អ្នក  ឬប្រើលិខិតឥណទាន  ឬប្រើទីភ្នាក់ងារហិរញ្ញវត្ថុប្រមូលបំណុលដើម្បីបង្កើនអត្រាទូទាត់ប្រាក់នៃគណនីដែលត្រូវទទួល។ | ✓ | »»» »»»<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| ទាក់ទងធនាគាររបស់អ្នកដើម្បីពិភាក្សាអំពីប្រាក់កម្ចីរយៈពេលខ្លី និងមធ្យមបន្ថែមទៀតដើម្បីពង្រឹងសន្ទនីយភាពរបស់អ្នក។ អ្នកអាចប្រើផ្នែកខ្លះនៃរោងចក្ររបស់អ្នក (ឧទាហរណ៍ដូចជាម៉ាស៊ីន) ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនដាក់ជាទ្រព្យបញ្ចាំ។ | ✓✓ | »»» »»»<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| ពិភាក្សាជាមួយធនាគារ និងអ្នកផ្គត់ផ្គង់របស់អ្នកអំពីវិធីរៀបចំបំណុលរយៈពេលខ្លី និងមធ្យមរបស់អ្នកឡើងវិញ។ ការទូទាត់សងកាន់តែតិច / ការទូទាត់សងដែលត្រូវបានពន្យាពេល និងអត្រាការប្រាក់កាន់តែទាបនឹងជួយកាត់បន្ថយលំហូរចេញប្រចាំខែរបស់អ្នក។ | ✓ | »»» »»»<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| ពិនិត្យមើលហិរញ្ញវត្ថុរបស់អ្នក ហើយព្យាយាមរកវិធីដើម្បីពង្រឹងកម្រិតប្រាក់ចំណេញរបស់រោងចក្រអ្នក។ អ្នកអាចបង្កើនកម្រិតប្រាក់ចំណេញរបស់អ្នកតាមរយៈដូចជា៖ ការកែលម្អ | ✓✓ | »»» »»»<br>រយៈពេលខ្លី / | ☐ |

| | | | |
|---|---|---|---|
| ប្រព័ន្ធ និងការអនុវត្តរោងចក្ររបស់អ្នកដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព និងតាមរយៈការបណ្ដុះបណ្ដាលកម្លាំងពលកម្មរបស់អ្នក។ | | រយៈពេលមធ្យម | |
| ព្យាយាមកាត់បន្ថយលំហូរចេញនៃសាច់ប្រាក់របស់អ្នកតាមដែលអាចធ្វើទៅបាន ហើយស្នើសុំឱ្យអ្នកផ្គត់ផ្គង់របស់អ្នកផ្ដល់ពេលវេលាបន្ថែមដើម្បីអាចទូទាត់ចំណាយរបស់អ្នក។<br>**គន្លឹះមានប្រយោជន៍៖** សូមមើលគោលការណ៍ណែនាំស្តីពី "ការកាត់បន្ថយចំណាយ" ជាផ្នែកមួយនៃស៊េរីនៃគោលការណ៍ណែនាំនេះ ដើម្បីស្វែងរកវិធីកាត់បន្ថយចំណាយសម្រាប់រោងចក្រអ្នក។ | ✓✓ | ››› ›››<br>រយៈពេលខ្លី /<br>រយៈពេលមធ្យម | ☐ |
| កាត់បន្ថយសន្និធិរបស់អ្នកដើម្បីចៀសវាងការស្តុកទំនិញនៅក្នុងឃ្លាំងរបស់អ្នករយៈពេលយូរពេក។ | ✓ | ››› ››› ›››<br>រយៈពេលមធ្យម/<br>រយៈពេលវែង | ☐ |

គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសហគ្រាសរបស់អង្គការ ILO សម្រាប់ **គម្រោងការងារសមរម្យនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់វិស័យកាត់ដេរនៅអាស៊ី** ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត។

សម្រាប់ឯកសារ ឬធនធានផ្សេងៗទៀតដើម្បីជួយអ្នកដោះស្រាយស្ថានភាពក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ សូមចូលទៅកាន់៖

▶ ilo.org/covid19

**ក្រុមការងារគាំទ្របច្ចេកទេសគម្រោងការងារសមរម្យ**
**សម្រាប់តំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក**
អគារអង្គការសហប្រជាជាតិ ជាន់ទី ១០ ផ្លូវ Rajdamnern Nok
ទីក្រុងបាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទលេខ៖ ៦៦២ ២៨៨ ១២៣៤ ទូរសារ៖ ៦៦២ ២៨៨ ៣០៥៨
អ៊ីម៉ែល៖ BANGKOK@ilo.org

DECENT WORK
A better world starts here.